# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១២

**១ . ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣. ១ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (ប្រធានអង្គប្រជុំ)

៣.២ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.៣ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៥៤រូប និងតាមប្រព័ន្ធអនឡាយចំនួន ២៧រូប សរុបចំនួន៨១រូប។

**៤. របៀបវារៈ៖**

៤.១ មតិស្វាគមន៍ បើកកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៤.២ មតិបើកកិច្ចប្រជុំ និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៤.៣ បទបង្ហាញស្តីពីលទ្ធផលការងារក្រុមប្រឹក្សាបច្ចេកទេសប្រចាំឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ ២០២៣ ដោយ **លោកវេជ្ជបណ្ឌិត ហួត សេរីវុធ្ឍ** ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៤.៤ពិភាក្សាលើលទ្ធភាពផ្តល់ប័ណ្ណសមធម៌ ឬប័ណ្ណ ប.ស.ស. ដល់ក្រុមប្រជាជនគន្លឹះ ដោយ **ឯកឧត្តម វេជ្ជបណ្ឌិត ស៊ឹម សុផៃ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៤.៥ កិច្ចពិភាក្សារួម

៤.៦ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនជារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. លទ្ធផល ៖**

នៅថ្ងៃសុក្រ ១០រោចខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៦ខែធ្នូ ឆ្នាំ២០២២ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនឯកឧត្តមផ្ទាល់ ឯកឧត្តមបានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី១២ ឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមប្រព័ន្ធអនឡាយ ZOOM និងដោយផ្ទាល់នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ថ្វីត្បិតនៅឆ្នាំ២០២០ កម្ពុជាបានសម្រេចរួចហើយនូវគោលដៅ ៩០-៩០-៩០ យើងកំពុងជួបនូវឧបសគ្គ ក្នុងដំណើរឆ្ពោះទៅរកគោលដៅថ្មីមួយទៀតគឺ៩៥-៩៥-៩៥ នៅត្រឹមឆ្នាំ២០២៥ ដោយក្នុងនោះ គោលដៅ៩៥ ទី១ ទើបសម្រេចបាន ៨៤ភាគរយ គោលដៅ៩៥ ទី២ សម្រេចបាន ៩៩ភាគរយ និងគោលដៅ៩៥ ទី៣ សម្រេចបាន ៩៧ភាគរយ។ លទ្ធផលនេះ ចាំបាច់តម្រូវឱ្យមានការចូលរួមរៀបចំជាបន្តបន្ទាប់ថែមទៀត នូវគោលនយោបាយ និងយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងជាពហុវិស័យ ប្រកបដោយនវានុវត្តន៍ និងបរិយាប័ន្ន ដើម្បីប្រើប្រាស់ជាមគ្គុទេសន៍តម្រង់ផ្លូវ ជាពិសេសគោរពយ៉ាងខ្ជាប់ខ្ជួនទៅនឹងផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា និងសេចក្តីប្រកាសនៃការប្តេជ្ញាចិត្ត ក្នុងការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ របស់រាជរដ្ឋាភិបាល តាមរយៈសេចក្តីជូនដំណឹងលេខ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍គន្លឹះសម្រាប់ការសិក្សាលទ្ធភាព និងរបៀបនៃការផ្តល់ប័ណ្ណសមធម៌ ឬប័ណ្ណ ប.ស.ស. ដល់ប្រជាជនគន្លឹះ ជាពិសេសអ្នកបម្រើក្នុងសេវាកំសាន្តដែលក្រីក្រគ្មានផ្ទះសម្បែងដោយ ចាត់តាំងជាក្រុមពីរៈ

១.ក្រុមប្រមូល និងវិភាគទិន្នន័យក្រុមប្រជាជនគន្លឹះដើម្បីឱ្យមានព័ត៌មានច្បាស់លាស់សម្រាប់ការសម្រេចគោលនយោបាយ។

២. ក្រុមប្រមូលឯកសារ និងសិក្សាពីនីតិវិធីផ្តល់ប័ណ្ណសមធម៌ ឬប័ណ្ណ ប.ស.ស. ដល់ប្រជាជនគន្លឹះ ជាពិសេសអ្នកបម្រើក្នុងសេវាកំសាន្តដែលក្រីក្រគ្មានផ្ទះសម្បែង។

ដំណើរការនៃកិច្ចប្រជុំមាន៖

**ឯកឧត្តមបណ្ឌិត ឈឹម ឃិន**ជារ៉េត អគ្គលេខាធិការ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបញ្ជាក់ថា ប្រទេសកម្ពុជាយើង នៅមានឧបសគ្គក្នុងការសម្រេចឱ្យបាននូវគោលដៅ៩៥ ៩៥ ៩៥។ លើសពីនេះ យើងត្រូវផ្តោតទៅលើវិធានការ ៦ចំណុច ដើម្បីធានាចីរភាពក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល តាមសេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

បទបង្ហាញស្តីពីលទ្ធផលការងារក្រុមប្រឹក្សាបច្ចេកទេសប្រចាំឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ ដោយ**លោកវេជ្ជបណ្ឌិត ហ្វូត សេរីវុធ្ធ** ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ក្នុងឆ្នាំ២០២២ នេះក្រុមប្រឹក្សាបច្ចេកទេសបានរៀបចំកិច្ចប្រជុំចំនួន១២លើក រួមមាន៖

- ២៨ ខែមករា ឆ្នាំ២០២២ ប្រធានបទ ពិនិត្យ វាយតម្លៃ ពាក់កណ្តាលអាណត្តផែនការយុទ្ធសាស្ត្រជាតិលើកទី៥
- ២៥ ខែកុម្ភៈ ២០២២ ប្រធានបទ វឌ្ឍនភាពគម្រោង PrEP ក្នុងការការពារមេរោគអេដស៍
- ២៥ ខែមីនា ឆ្នាំ២០២២ ប្រធានបទ កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន PMTCT និងការបញ្ចប់ការចម្លងអេដស៍នៅឆ្នាំ២០២៥ ដោយផ្តោតលើ ១.ស្ថានភាពបច្ចុប្បន្នភាពការចម្លងពី ម្តាយទៅកូន ២.សូចនាករនៃការប្តេជ្ញាចិត្តការបញ្ចប់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ៣.បទអន្តរាគមន៍ និងវឌ្ឍនភាព (TWG on PMTCT) ៤.ជំហ៊ានបន្ទាប់ ។
- ២៥ ខែមេសា ២០២២ ប្រធានបទ ១.ពិភាក្សាការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ណែនាំស្តីពីការបង្ការនៃការចម្លងមេរោគអេដស៍ជាសកល ២.ពិភាក្សាលើការធ្វើនវានុវត្ត និងបរិយាប័ន្ន សារ សម្ភារ និងមធ្យោបាយអប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីអេដស៍៖ផ្តោតសំខាន់លើក្រុមប្រជាជនគន្លឹះ។
- ២៥ ខែឧសភា ២០២២ ប្រធានបទ ១.វឌ្ឍនភាពស្តីពីការសម្រេចបានគោលដៅ៩៥-៩៥-៩៥ (២០២០-២០២២) ២. តើការសម្រេចបានគោលដៅ៩៥-៩៥-៩៥ រាជធានីខេត្ត? ខេត្តណាខ្លះសម្រេចបាន? ខេត្តណាខ្លះមិនទាន់បានសម្រេច? មូលហេតុ? ៣. វឌ្ឍនភាព និងសមិទ្ធផលនៃការថែទាំ និងព្យាបាល (និន្នាការចំនួនទីកន្លែងផ្តល់សេវាព្យាបាលដោយ ARV (2001-2022) ៤.វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការតាមក្រុមប្រឈម និង

ការធ្វើតេស្តរក មេរោគអេដស៍៥. បញ្ហាប្រឈម ៦.ជំហ៊ានបន្ទាប់ឈានទៅសម្រេចគោលដៅ៩៥-៩៥-៩៥។

- ២០ ខែ មិថុនា ឆ្នាំ២០២២ ប្រធានបទ ពិគ្រោះយោបល់លើរបាយការណ៍អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ប្រធានបទ ១. អំពីតួនាទីរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតួនាទីរបស់ក្រុមប្រឹក្សាបច្ចេកទេស និងតួនាទីក្រុមយុទ្ធសាស្ត្រ២. ពិភាក្សាលើសេចក្តីព្រាង សេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ឆ្នាំ២០២២។
- ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ប្រធានបទ ១. ពិភាក្សាលើការកំណត់អាទិភាពអនុសាសន៍នៃការពិនិត្យឡើងវិញNSP Vសម្រាប់សិក្ខាសាលាឆ្លុះបញ្ចាំងកម្រិតខ្ពស់ស្តីពីការឆ្លើយតបមេរោគអេដស៍ពហុវិស័យនៅកម្ពុជា២. ពិភាក្សាលើសេចក្តីព្រាងនៃរបាយការណ៍សង្ខេប និងសូចនាករសំខាន់ៗ ដែលជាសមិទ្ធផលរយៈពេល៥ឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី6 នៃរដ្ឋសភា (ចាប់ពីឆ្នាំ២០១៣ ដល់ខែកញ្ញា ឆ្នាំ២០២២) របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០២២ ប្រធានបទ ស្តីពីលទ្ធផលពាក់កណ្តាលអាណត្តិនៃការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។
- ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ប្រធានបទ ស្តីពីការងារតាមដានដឹកនាំដោយសហគមន៍ (Community-Led Monitoring)
- ថ្ងៃទី១៨ ខែវិច្ឆកា ឆ្នាំ២០២២ ប្រធានបទ កិច្ចពិភាក្សាលើសេចក្តីព្រាងនៃរបាយការណ៍នៃកិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០២២ និងសន្និបាតស្តីពីការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣/២៤ ខែវិច្ឆិកាឆ្នាំ២០២២។
- ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ប្រធានបទ ១. លទ្ធផលការងារក្រុមប្រឹក្សាបច្ចេកទេសប្រចាំឆ្នាំ ២០២២ ២. ពិភាក្សាពីលទ្ធភាពផ្តល់ប័ណ្ណប.ស.ស ឬ ប័ណ្ណសមធម៌ដល់ប្រជាជនគន្លឹះ

ទិសដៅ និងជំហានបន្តទទួលធាតុចូលពីក្រុមការងារតាមយុទ្ធសាស្ត្រ និងពិភាក្សាសម្រេចលើសកម្មភាពមួយចំនួនដូចខាងក្រោម៖

1. គោលនយោបាយបញ្ចប់អេដស៍ និងនិរន្តរភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍

2. បញ្ចប់បច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយនិរន្តរភាពនៅ កម្ពុជា ( Updated HIV Sustainability Roadmap in Cambodia )
3. ផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៦ សម្រាប់ឆ្នាំ២០២៤-២០២៨ ឈានទៅការបញ្ចប់អេដស៍ និងនិរន្តរភាពនៃការឆ្លើយតបមេរោគអេដស៍នៅកម្ពុជា ( National Strategic Plan on HIV Elimination and Sustainability Response in Cambodia )
4. ប្រព័ន្ធជាតិស្តីពីការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅប្រទេសកម្ពុជា ( Country System for HIV and AIDS response )
5. បច្ចុប្បន្នភាព AIDS Epidemic Model 2023 ដោយប្រើប្រាស់នូវទិន្នន័យ ឆ្នាំ២០២២ ។
6. បច្ចុប្បន្នភាព Optima និងដើម្បីប្រើប្រាស់ជាឧបករណ៍សម្រាប់ស្វែករកការគាំទ្រការវិភាជន៍ថវិការឱ្យបានសមស្រប និងបានចំទិសដៅ និងកានតែមានប្រសិទ្ធិភាព
7. កិច្ចសន្យាសង្គមក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា( Social contracting on HIV and AIDS in Cambodia ) និងការជំរុញការផ្តល់បណ្ណសមធម៌ ដល់អ្នកផ្ទុកមេរោគអេដស៍។

បន្តតាមដានត្រួតពិនិត្យដូចខាងក្រោម៖

1. ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការបង្ការមេរោគអេដស៍ កាមរោគ និងការព្យាបាល ក្នុងវិស័យសុខាភិបាល ( Midterm Review of National Strategic Plan for HIV/AIDS and STI Prevention and Care in Health Sector )
2. ការកៀរគរហិរញ្ញប្បទានក្នុងស្រុក និងក្រៅស្រុក និងកំណត់អាទិភាពសកម្មភាពសម្រាប់ពង្រឹងប្រព័ន្ធជាតិ ( Country System ) ដើម្បីចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។ សម្របសម្រួលសំណើរគម្រោងឆ្លើយតបមេរោគអេដស៍ សម្រាប់មូលនិធិសកល GF 2024-2026
3. ការអនុវត្តលិខិតលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ អំពីការដាក់វិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដោយបន្តចុះបណ្តុះបណ្តាលការត្រួតពិនិត្យការអនុវត្តសជណ២១៣ នៅរាជធានី និងបណ្តាខេត្តគោលដៅ។
4. ត្រួតពិនិត្យ វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ ដែលស្ថិតក្រោមក្រុមប្រឹក្សា

បច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើរតួនាទីចម្បងក្នុងការប្រមូលព័ត៌មាន ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់អំពីវឌ្ឍនភាព នៃការអនុវត្តផែនយុទ្ធសាស្ត្រ។

5. បន្តជំរុញការអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ (Fast-Track Cities: Ending the AIDS Epidemic) នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប។ សម្របសម្រួលការរៀបចំផែនការសកម្មភាព ថវិកាឆ្លើយតបមេរោគអេដស៍ នៅតាមបណ្តាក្រសួង។ រៀបចំផែនការសកម្មភាព ថវិកា សម្រាប់ខេត្ត ១១ ផ្សេងទៀត ដោយប្រើប្រាស់ថវិកាជាតិ ៦០ លានរៀល/ខេត្ត ។
6. ជំរុញការរៀបចំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដោយបញ្ចូលសមាសភាពពាក់ព័ន្ធនានា រួមមានតំណាងអ្នកផ្ទុកមេរោគអេដស៍ និងតំណាងប្រជាជនគន្លឹះ បន្ថែមទៅក្នុងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.)។

ជាបន្តឯក**ឧត្តមវេជ្ជ. ស៊ឹម សុផៃ** អគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានបង្ហាញពី ពិភាក្សាលើលទ្ធភាពផ្តល់ប័ណ្ណសមធម៌ ប័ណ្ណ ប.ស.ស. ដល់ក្រុមប្រជាជនគន្លឹះ៖

**ឯកឧត្តមវេជ្ជបណ្ឌិត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរាយការណ៍សង្ខេបលើស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍តាមការប៉ាន់ប្រមាណក្នុងឆ្នាំ២០២២ មានប្រជជានដែលផ្ទុកមេរោគអេដស៍ចំនួន៧៤០០០នាក់ ក្នុងនោះបានដឹងពីស្ថានភាពខ្លួនឯង៨៤% ទទួលការព្យាបាល៩៩% និងViral load suppression ៩៨% ឆ្លងថ្មី ១១០០នាក់(គោលដៅរបស់យើង ២៥០នាក់ក្នុង១ឆ្នាំ នាឆ្នាំ២០២៥) និងស្លាប់១១០០នាក់។ ដោយផ្តោតលើអត្រាឆ្លងក្នុងចំណោមប្រជាជនទូទៅអាយុពី១៥ឆ្នាំ ដល់៤៩ឆ្នាំ មាន០.៦% នៅឆ្នាំ២០២១ និងអត្រាឆ្លងក្នុងចំណោមក្រុមប្រឈមដូចជា៖

- ក្រុមស្ត្រីសេវាកម្សាន្ត ៤.៩% នៅឆ្នាំ២០២២
- ក្រុមស្ត្រីសេវាកម្សាន្តឯករាជ្យ ៦.៩% នៅឆ្នាំ២០២២
- ក្រុមបំប្លែងភេទ ៩.៦% នៅឆ្នាំ ២០១៩
- ក្រុមបុរសរួមភេទជាមួយបុរស ៤.0% នៅឆ្នាំ ២០១៩
- ក្រុមប្រើប្រាស់គ្រឿងញៀនដោយចាក់ ១៥.២% នៅឆ្នាំ ២០១៧
- ក្រុមប្រើប្រាស់គ្រឿងញៀនដោយមិនចាក់ ៥.៧% នៅឆ្នាំ ២០១៧

ក្នុងនោះឯកឧត្តមក៏បានបញ្ជាក់ជោគជ័យរបស់កម្ពុជា ក្នុងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍លើ ៩៥%ទី២បានសម្រេច៩៩% និង៩៥%ទី៣ បានសម្រេច៩៧% ចំណែកឯ៩៥% ទីមួយ មិនទាន់សម្រេចគោលដៅនៅឡើយទេ បានតែ៨៤%ប៉ុណ្ណោះ។ ចំនួន និងភាគរយអ្នកជំងឺអេដស៍បានប្រើប្រាស់ប័ណ្ណគ្រួសារក្រីក្រ ក្នុងត្រីមាសទី៣ ឆ្នាំ២០២២ មានចំនួន៨៦៨៣នាក់ ក្នុងចំនួន ៦៤២០៩នាក់ ប្រមាណ ១៣.៥២% ប៉ុណ្ណោះ។ ចំនួនក្រុមប្រជាជនគន្លឹះសរុបមាន ៩៤៣៥៤នាក់

មានប្រជាជនតំរូវការប័ណ្ណសមធម៌ ១៩៣៧៦នាក់ តួលេខនេះគ្រប់ដណ្តប់២១ រាជធានីខេត្ត ទទួលបានពី អង្គការវ៉ាក់ និងអង្គការខាន់ណា ដែលប័ណ្ណសមធម៌របស់អ្នកផ្ទុកមេរោគអេដស៍មិនមានផុតសុពលភាព នោះទេ។

កិច្ចពិភាក្សារួមផ្តោតសំខាន់កំណត់លើប្រជាជនគន្លឹះ MSM TG ឬ EW និងចំពោះប្រជាជនគន្លឹះ ដែលគ្មានទីលំនៅ និងទីកន្លែងធ្វើការពិតប្រាកដ(នៅតាមសួន និងផ្លូវ) និងសម្រាប់អ្នកដែលធ្វើការនៅក្នុង សហគ្រាសដែលមានប័ណ្ណ បសស ៖

- លោក អ៊ីង ប៊ូនលីន តំណាង UNAISD គួរតែដាក់ក្រុមប្រជាជនគន្លឹះដែលមានផ្ទះសម្បែង មានជីវិភាពក្រីក្រជាអទិភាព ដូចក្រុមប្រជាជនគន្លឹះដែលធ្វើការតាមសួន និងគ្មានផ្ទះ សម្បែងផងដែរ និងលើកជាសំនួរថា តើទិន្នន័យចំនួនក្រុមប្រជាជនគន្លឹះ ដែលទទួលបាន ពីអង្គការវ៉ាក់ និងអង្គការខ៉ាន់ណា មានភាពច្បាស់លាស់បានប៉ុនណា?
- លោកវេជ្ជ.ង៉ូវ បូរ៉ា ចំពោះចំនួនក្រុមប្រជាជនគន្លឹះគួរតែកាត់បន្ថយតួរលេខជាន់គ្នា រវាងក្រុម ប្រជាជនដែលមានប័ណ្ណសមធម៌ ឬប័ណ្ណបសស និងអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។
- ឯកឧត្តម កែវ អ៊ូលី ក៏មានគំនិតដូចការលើកឡើងរបស់លោកវេជ្ជ.ង៉ូវ បូរ៉ាដែរ ដោយយើង បានប្រកាសនីតិវិធីសម្រាប់កំណត់អត្តសញ្ញាណគ្រួសារដែលមានផ្ទុកមេរោគអេដស៍ ស្រប តាមសជណ ២១៣ ដោយផ្តល់ជាលក្ខណបុគ្គល និងស្ម័គ្រចិត្ត ។ ឯកឧត្តមក៏ស្នើប្រើ យន្តការ ឃុំ សង្កាត់ ចំពោះក្រុមប្រជាជនគន្លឹះដែលក្រុមគ្រួសារមានប័ណ្ណសមធម៌ ធ្វើការ ចំណាក់ស្រុក ស្នើទៅឃុំ សង្កាត់ ដើម្បីធ្វើបច្ចុប្បន្នភាព ទទួលបានសេវាសង្គម។
- លោកស្រី អ៊ុក សុម៉ាល័យ តំណាងស្ត្រីធ្វើការសេវាកំសាន្ត និងតំណាងវេទិការ Fonpan de Fonpan លើកឡើងថាក្រុមប្រជាជនគន្លឹះមានដែលចង់បានប័ណ្ណក្រីក្រ មានដល់ ៧៣% ខណៈដែលទទួលបានត្រឹម២២% ចំពោះបញ្ហាពួកគាត់ជួបប្រទះ មិនមានឯកសារគ្រប់ គ្រាន់ អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ សំបុត្រកំណើត ចំណាក់ ស្រុក មិនមានសាច់ញាតិ និងមិនទទួលពត័មានគ្រប់គ្រាន់ ។
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកឡើងថាការលំបាក់ របស់ក្រុមប្រជាជនគន្លឹះ ឬ ក៏ក្រុមប្រជាជនរស់នៅជាមួយមេរោគអេដស៍ រាជរដ្ឋាភិបាលមិនទុកចោល នឹងប្រឹងប្រែង តាមលទ្ធភាពជាក់ស្តែង យើងត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណពួកគាត់នៅក្នុង ឃុំ សង្កាត់ ថាពួកគាត់ស្ថិតនៅក្នុងក្រុមគ្រួសារទទួលបានប័ណ្ណសមធម៌ហើយឬនៅ?

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បាន ឯកភាពគ្នាធ្វើការសិក្សាលើក្រុមប្រជាជនគន្លឹះ ដោយបង្កើតក្រុមការងារមួយសិក្សាពីទិន្នន័យដើម្បីបាន តួលេខ និងព័តមានគ្រប់គ្រាន់ ដឹកនាំដោយឯកឧត្តមវេជ្ជ.ស៊ឹម ស្ងៃ លោកវេជ្ជ.ង៉ូវ ប៉ូរ៉ា តំណាងអង្គការវ៉ាក់ អង្គការខ៉ាន់ណា អង្គការFHI 360 តំណាងក្រុមប្រជាជនគន្លឹះ សម្រាប់ប្រជុំប្រឹក្សាបច្ចេកទេសខែក្រោយ។

ប្រធានអង្គប្រជុំ ក៏បានបន្ថែមថា ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នារវាង គឺធ្វើតាមវិធីសាស្ត្រនៃការចូលរួមជាមួយគ្នាគឺ អ្នកធ្វើគោលនយោបាយ យុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងសហគមន៍ ដោយយកប្រជាជនជាស្នូល។

សម្រាប់កិច្ចប្រជុំលើកទី១ ឆ្នាំ២០២៣ នឹងកំណត់យក នៅថ្ងៃសុក្រ ៨រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ( Zoom )ដោយកំណត់យករបៀបវារៈមាន "បន្តកិច្ចពិភាក្សាលើលទ្ធភាពផ្តល់ប័ណ្ណសមធម៌ឬប័ណ្ណប.ស.ស.ដល់ក្រុមប្រជាជនគន្លឹះ"៕

ថ្ងៃសុក្រ ១កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២
អ្នកធ្វើរបាយការណ៍

**ប្រធានអង្គប្រជុំ**

**ឈឹម ឃិនដារ៉េត**